ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ប្រព័ន្ធបញ្ជរតែមួយជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៥ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើ៖ ១.កិច្ចព្រមព្រៀងស្តីពីការបង្កើតនិងការអនុវត្តបញ្ជរតែមួយអាស៊ាន ២.ពិធីសារស្តីពីការបង្កើតនិងការអនុវត្តបញ្ជរតែមួយអាស៊ាន ៣.ពិធីសារស្តីពីក្របខណ្ឌច្បាប់សម្រាប់អនុវត្តបញ្ជរតែមួយអាស៊ាន

- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៧០ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការដាក់ឱ្យប្រើបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីការគ្រប់គ្រងនិងកិច្ចដំណើរការប្រព័ន្ធបញ្ជរតែមួយជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការស្នើសុំនិងការផ្ដល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀត សម្រាប់ការនាំចេញ នាំចូល ឬទំនិញឆ្លងកាត់ដូចខាងក្រោម៖

- ទំនិញហាមឃាត់ និងជាប់កម្រិតកំណត់
- ទំនិញស្ថិតក្នុងកាតព្វកិច្ចនៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
- ទំនិញស្ថិតក្នុងកាតព្វកិច្ចនៃការអនុវត្តអនុសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត
- ផលិតផលគេលសិលា និងទំនិញនៃអគារលក់ទំនិញរួចពន្ធ
- ទំនិញទទួលបានការលើកលែងពន្ធនិង/ឬអាករ របស់គម្រោងវិនិយោគ
- ទំនិញទទួលបានការលើកលែងពន្ធនិងអាកររបស់ក្រសួង ស្ថាប័ន បេសកកម្មការទូត បេសកកម្មកុងស៊ុលបរទេស និងអង្គការជាតិ/អន្តរជាតិនានា
- ទំនិញទទួលបានការលើកលែងពន្ធនិងអាករផ្សេងទៀត តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ប្រព័ន្ធបញ្ជរតែមួយជាតិ** សំដៅដល់ថ្នាលបច្ចេកវិទ្យាព័ត៌មានដែលអនុញ្ញាតឱ្យបុគ្គលដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល និងទំនិញឆ្លងកាត់អាចស្នើសុំ អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងឯកសារតម្រូវផ្សេងទៀត ទៅគ្រប់ក្រសួង ស្ថាប័ន មានសមត្ថកិច្ចតែមួយលើករួមគ្នា ដើម្បីទទួលបាននូវការអនុញ្ញាត សម្រាប់យកទៅប្រើក្នុងការបំពេញបែបបទបញ្ចេញទំនិញពីគយ តាមប្រព័ន្ធអេឡិចត្រូនិក។

- **ប្រព័ន្ធអេឡិចត្រូនិក** សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នាឬទាក់ទងគ្នាតាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។
- **ទិន្នន័យ** សំដៅដល់បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬកម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើក្នុងមូលដ្ឋានទិន្នន័យឬប្រព័ន្ធអេឡិចត្រូនិក។
- **ប្រធានសក្តិ** សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅពីឆន្ទៈមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ។

**មាត្រា៥ .-**

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀតតាមប្រព័ន្ធបញ្ជរតែមួយជាតិ ដែលមានអាសយដ្ឋាន https://nsw.gov.kh សម្រាប់មុខទំនិញដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ស្របតាមមាត្រា២នៃអនុក្រឹត្យនេះ។

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធត្រូវកំណត់អំពីនីតិវិធីលម្អិតបន្ថែម ពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀត តាមតម្រូវការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការនិងការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ។

**មាត្រា៦ .-**

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការនិងផ្លាស់ប្តូរទិន្នន័យ ឯកសារ និងព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៣
## ការប្រើប្រព័ន្ធបញ្ជរតែមួយជាតិ

**មាត្រា៧ .-**

បុគ្គលដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល និងទំនិញឆ្លងកាត់ អាចចូលប្រើប្រព័ន្ធបញ្ជរតែមួយជាតិ មានដូចជា៖

- មន្ត្រីដែលមានសមត្ថកិច្ចនៃក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គការ ស្ថានទូត ឬស្ថានកុងស៊ុល
- អ្នកនាំចេញនាំចូល



៤

- ជើងសាគយ និង
- បុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពីក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ។

**មាត្រា៨ .-**

បុគ្គលដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំចុះឈ្មោះដើម្បីចូលប្រើប្រព័ន្ធបញ្ជរតែមួយជាតិ ស្របតាមបែបបទនិងនីតិវិធីដែលកំណត់ដោយក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ។

**មាត្រា៩ .-**

ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ និងបុគ្គលដូចមានចែងក្នុងមាត្រា៧ ខាងលើត្រូវ៖

- រក្សាសុវត្ថិភាពទិន្នន័យ ព័ត៌មាន និងគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌ ការសម្ងាត់វិជ្ជាជីវៈ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និង
- ទទួលខុសត្រូវលើទិន្នន័យដែលខ្លួនបានបង្កើត កែសម្រួល ផ្លាស់ប្តូរ ឬធ្វើបច្ចុប្បន្នភាពក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ។

**មាត្រា១០ .-**

ប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួង ស្ថាប័ននានាតាមការចាំបាច់ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការផ្លាស់ប្តូរទិន្នន័យឬឯកសារពាណិជ្ជកម្មក្នុងទម្រង់អេឡិចត្រូនិក។

**មាត្រា១១ .-**

ប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធបញ្ជរតែមួយអាស៊ាន និង/ឬ ប្រព័ន្ធអេឡិចត្រូនិករបស់ប្រទេសដៃគូពាណិជ្ជកម្មនានា ដើម្បីផ្លាស់ប្តូរទិន្នន័យឬឯកសារពាណិជ្ជកម្មឆ្លងកាត់ព្រំដែនក្នុងទម្រង់អេឡិចត្រូនិកជាមួយបណ្តាប្រទេសទាំងនោះ ស្របតាមកិច្ចព្រមព្រៀងពាក់ព័ន្ធនានាដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។

## ជំពូកទី៤
## កិច្ចដំណើរការប្រព័ន្ធបញ្ជរតែមួយជាតិ

**មាត្រា១២ .-**

ការស្នើសុំអាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀតត្រូវធ្វើឡើងដោយម្ចាស់ទំនិញ ឬតំណាងដែលទទួលបានការអនុញ្ញាតឱ្យបំពេញបែបបទក្នុងនាមម្ចាស់ទំនិញដោយត្រូវផ្តល់ព័ត៌មានស្របតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៣ .-**

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធ មានភារកិច្ចពិនិត្យនិងសម្រេចលើការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀត ដោយផ្អែកលើគោលការណ៍ហានិភ័យស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រសួង ស្ថាប័ន មានសមត្ថកិច្ចពាក់ព័ន្ធត្រូវពិនិត្យនិងសម្រេចក្នុងរង្វង់រយៈពេល ៣ (បី)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីពេលទទួលបានការស្នើសុំនិងឯកសារគ្រប់គ្រាន់តាមការកំណត់។

ក្នុងករណីប្រធានសក្តិឬដោយសារបញ្ហាបច្ចេកទេសជាយថាហេតុ បណ្តាលឱ្យប្រព័ន្ធបញ្ជរតែមួយជាតិ ឬប្រព័ន្ធរបស់ក្រសួង ស្ថាប័ន មិនអាចដំណើរការបាន ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធអាចចាត់ចែងអនុវត្តនីតិវិធីនៅក្រៅប្រព័ន្ធជាបណ្តោះអាសន្នតាមបទប្បញ្ញត្តិជាធរមាន ដោយត្រូវជូនដំណឹងមកគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ និងក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិ រហូតដល់ប្រព័ន្ធដំណើរការឡើងវិញ។

**មាត្រា១៤ .-**

ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិត្រូវ៖

- គ្រប់គ្រងនិងផ្តល់គណនីប្រើប្រព័ន្ធជូនបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យនេះស្របតាមការស្នើសុំ
- ថែទាំ រក្សាសុវត្ថិភាព និងធ្វើបច្ចុប្បន្នកម្មប្រព័ន្ធបញ្ជរតែមួយជាតិ និង
- សម្របសម្រួលដើម្បីពង្រីកការតភ្ជាប់ ធានានិរន្តរភាពក្នុងការងារតភ្ជាប់ និងកិច្ចដំណើរការនៃប្រព័ន្ធរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៥
## កម្រៃសេវាសាធារណៈ

**មាត្រា១៥ .-**

ការយកកម្រៃសេវាសាធារណៈសម្រាប់ការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងការអនុញ្ញាតផ្សេងទៀតតាមប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៦ .-**

រាល់ការទូទាត់កម្រៃសេវាសាធារណៈក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិក លើកលែងមានការកំណត់ដោយឡែក។

ក្រុមអនុវត្តគម្រោងបញ្ជរតែមួយជាតិត្រូវបន្តសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកប្រព្រឹត្តទៅដោយរលូន ពេញលេញ និងមានប្រសិទ្ធភាព។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៧ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកិច្ចដំណើរការតាមប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវបន្តនិរន្តរភាពរបស់ខ្លួន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



៥

**មាត្រា១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការដឹកនាំ**

**គម្រោងបញ្ជរតែមួយជាតិ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ